**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ សៅរ៍ ៩ កើត ខែ ជេស្ឋ ឆ្នាំ រោង ឆស័ក ព.ស. ២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ខួបគម្រប់ ៤ ឆ្នាំនៃការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវ ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន

គិតត្រឹមថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២៤, ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន (ប្រព័ន្ធ Online Business Registration - OBR) ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការបានរយៈពេល ៤ ឆ្នាំមកហើយ។ ប្រព័ន្ធ OBR ត្រូវបានអភិវឌ្ឍឡើងក្នុងគោលបំណងជួយសម្រួលដល់នីតិវិធីនៃការចុះបញ្ជីអាជីវកម្ម សំដៅចូលរួមលើកកម្ពស់បរិយាកាសធុរកិច្ចនៅកម្ពុជាឱ្យប្រសើរឡើង។ ប្រព័ន្ធនេះបាន និង កំពុងពង្រីកការដ្ឋានរហូតដល់ ៣ ដំណាក់កាល គឺចាប់តាំងពីត្រឹមការចុះបញ្ជីអាជីវកម្មជាកញ្ចប់នៅដំណាក់កាលទី ១ ឈានដល់ដំណាក់កាលទី ២ និង ដំណាក់កាលទី ៣ ដែលគ្របដណ្តប់បន្ថែមដល់ការផ្តល់អាជ្ញាបណ្ណ លិខិតអនុញ្ញាត និង វិញ្ញាបនបត្រ ផ្អែកលើសកម្មភាពអាជីវកម្មតាមវិស័យនានាផងដែរ។

ប្រព័ន្ធចុះបញ្ជីអាជីវកម្មតាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ១ (Single Portal) ដែលត្រូវបានដាក់ដំណើរការជាផ្លូវការលើកដំបូង កាលពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ជាការចុះបញ្ជីជាខ្សែប្រវាក់ ដោយមានរួមបញ្ចូលទាំងការចុះបញ្ជីពាណិជ្ជកម្មដោយក្រសួងពាណិជ្ជកម្ម, ការចុះបញ្ជីពន្ធដារដោយអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, និង ការប្រកាសសេចក្តីជូនដំណឹងបើកសហគ្រាស ដោយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ហើយក្រោយមកនៅពាក់កណ្តាលឆ្នាំ ២០២៣ បានបន្ថែមការចុះបញ្ជិកាសហគ្រាស-គ្រឹះស្ថាន នៅបេឡាជាតិសន្តិសុខសង្គម មួយទៀត)។ ការណ៍នេះអនុញ្ញាតឱ្យធុរជនអាចបំពេញនីតិវិធីដល់ទៅ ៤ ក្រសួង ស្ថាប័ន ក្នុងពាក្យស្នើសុំតែមួយ ដែលពាក្យស្នើសុំនេះត្រូវបានសម្រួលមកខ្លី និង សាមញ្ញជាងមុន ហើយអាចចុះបញ្ជីដោយជោគជ័យ ក្នុងរយៈពេលត្រឹម ៨ ថ្ងៃនៃថ្ងៃធ្វើការ ប្រសិនបើពាក្យស្នើសុំនោះបំពេញបានត្រឹមត្រូវ និង ពេញលេញ។ បន្ថែមពីនេះ, ធុរជនក៏អាចស្នើសុំចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (Qualified Investment Project – QIP) ផងដែរ។ ដំណាក់កាលទី ២ ត្រូវបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការ នៅថ្ងៃទី ១ ខែ កញ្ញា ឆ្នាំ ២០២១ និង ដំណាក់កាលទី ៣ បានដាក់ដំណើរការជាផ្លូវការ កាលពីថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ២០២៣ ដោយគ្របដណ្តប់បន្ថែមដល់ការផ្តល់អាជ្ញាបណ្ណ វិញ្ញាបនបត្រ/លិខិតអនុញ្ញាតជំនាញ ពីក្រសួង ស្ថាប័នពាក់ព័ន្ធ។ គិតមកដល់ពេលបច្ចុប្បន្ន, មានក្រសួង ស្ថាប័នចំនួន ២០ ហើយដែលបានបញ្ចូលសេវាសាធារណៈរបស់ខ្លួន សរុបចំនួន ៣១ មកក្នុងប្រព័ន្ធ OBR ។

លើសពីនេះ, មុខងារសំខាន់ចំនួន **៣** ដូចខាងក្រោម ត្រូវបានបន្ថែមនៅលើប្រព័ន្ធ Single Portal ៖

**មុខងារទី១ ៖** អនុញ្ញាតឱ្យក្រុមហ៊ុន/សហគ្រាសដែលបានចុះបញ្ជីពាណិជ្ជកម្ម តែមិនបានចុះបញ្ជីពន្ធដារ ឬ ដែលបានចុះបញ្ជីពន្ធដារតែមិនបានចុះបញ្ជីពាណិជ្ជកម្ម អាចចុះបញ្ជីបង្គ្រប់នីតិវិធីលើប្រព័ន្ធ Single Portal បាន។

**មុខងារទី២ ៖** អនុញ្ញាតឱ្យស្នើសុំផ្ទេរសិទ្ធិគ្រប់គ្រងព័ត៌មានក្រុមហ៊ុន/សហគ្រាសពីគណនី CamDigiKey មួយទៅគណនី CamDigiKey មួយទៀត តាមរយៈប្រព័ន្ធ។

**មុខងារទី៣ ៖** អនុញ្ញាតឱ្យស្នើសុំកែតម្រូវព័ត៌មាន ក្នុងដំណាក់កាលបញ្ជូនត្រលប់ ដែលព័ត៌មានស្នើសុំកែតម្រូវនោះ មិនត្រូវធ្វើឱ្យប៉ះពាល់ដល់ទម្រង់ក្រុមហ៊ុន សហគ្រាស និង/ឬ ការទូទាត់សងប្រាក់ ដែលបានធ្វើឡើងរួចហើយទេ។

ទន្ទឹមនេះ, មុខងារចុះបញ្ជីកែប្រែព័ត៌មានក្រុមហ៊ុន សហគ្រាស ដំណាក់កាលទី ១ ដែលមានចំនួន ៥ រួមមាន៖ **(១)** មុខងារកែប្រែព័ត៌មានលម្អិតអាសយដ្ឋានទីស្នាក់ការចុះបញ្ជី, **(២)** មុខងារកែប្រែលក្ខន្តិកៈក្រុមហ៊ុន, **(៣)** មុខងារកែប្រែសកម្មភាពអាជីវកម្ម, **(៤)** មុខងារតម្កល់ប្រតិវេទន៍ប្រចាំឆ្នាំ និង **(៥)** មុខងារកែប្រែព័ត៌មានគណនីធនាគារ ក៏ត្រូវបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០២៤ កន្លងទៅដែរ។

ក្នុងរយៈពេល ៤ ឆ្នាំ នៃការអនុវត្តការងារនេះ, លេខាធិការដ្ឋាននៃក្រុមការងារអន្តរក្រសួងរៀបចំសេវាអេឡិចត្រូនិកសម្រាប់ធុរកិច្ច ក្រោមកិច្ចសហការជាមួយក្រុមការងារជំនាញនៃក្រសួង ស្ថាប័នពាក់ព័ន្ធ បានដោះស្រាយបញ្ហាជូនអ្នកប្រើប្រាស់ចំនួន **១៣ ៩៥៤** ករណី។ លេខាធិការដ្ឋានក៏បានរៀបចំផ្ទាំងផ្សព្វផ្សាយព្រឹត្តិបត្រ និង កម្មវិធីប្រកួតប្រជែងប្រចាំសប្តាហ៍ ចំនួន **៩៣២**, រៀបចំវីដេអូចំនួន **៥៩**, រៀបចំ និង ចូលរួមសិក្ខាសាលាផ្សព្វផ្សាយចំនួន **៦៨**, បញ្ចប់ការចាក់ផ្សាយកម្មវិធីពីនេះពីនោះរឿងចុះបញ្ជី **រដូវកាលទី ១**, កែសម្រួលមុខមាត់ថ្មីកំណែទី ២ នៃថ្នាលធុរកិច្ច business.gov.kh, និង បានបោះពុម្ពព្រឹត្តិបត្រប្រចាំឆ្នាំ ២០២៣ សម្រាប់ផ្សព្វផ្សាយពីវឌ្ឍនភាពការងារ ដោយបានចែកចាយទៅសាធារណជនផងដែរ។ សម្រាប់ការងារផ្នែកបទប្បញ្ញត្តិ, ក្រុមការងារសម្រេចបានបន្ថែមនូវអនុក្រឹត្យថ្មី ១ ទៀតគឺ **អនុក្រឹត្យស្តីពីការគ្រប់គ្រងថ្នាលសម្គាល់អត្តសញ្ញាណអតិថិជនឌីជីថលកម្ពុជា (CamDigiKey)** បន្ថែមពីលើអនុក្រឹត្យ ២ ធំៗ ដែលមានស្រាប់ គឺ អនុក្រឹត្យស្តីពីការចុះបញ្ជីអាជីវកម្មតាមប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និង អនុក្រឹត្យស្តីពីការផ្លាស់ប្តូរទិន្នន័យតាមរយៈថ្នាលផ្លាស់ប្តូរទិន្នន័យកម្ពុជា (CamDX)។

ក្នុងឱកាសអបអរសាទរខួបគម្រប់ ៤ ឆ្នាំនៃការដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវប្រព័ន្ធចុះអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន, លេខាធិការដ្ឋានសូមផ្តល់ជូននូវវឌ្ឍនភាពការងារជាតួលេខ ដូចខាងក្រោម៖

**១. ប្រព័ន្ធចុះបញ្ជីអាជីវកម្ម តាមថ្នាលបច្ចេកវិទ្យាព័ត៌មាន ដំណាក់កាលទី ១**

| **បរិយាយ** | **ពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៤** |
|---|---|
| ចំនួនពាក្យស្នើសុំចុះបញ្ជីអាជីវកម្មអនុម័តសរុប | **៣៦ ៥០៩** |
| ម្ចាស់អាជីវកម្មដែលជាស្ត្រី | **១៣ ៧៤៨**<br>(~៣៨% នៃចំនួនពាក្យស្នើសុំដែលត្រូវបានអនុម័ត) |
| ទំហំដើមទុនចុះបញ្ជីសរុប | **~៤៦ ទ្រីលានរៀល**<br>**ឬ~១១,១៣ ប៊ីលានដុល្លារអាម៉េរិក**<br>(១ ដុល្លារអាម៉េរិក = ៤១០០ រៀល) |
| ចំនួនពាក្យស្នើសុំបម្រុងទុកនាមករណ៍អនុម័តសរុប | **១៩ ៣៥៣** |
| ចំនួនប្រតិបត្តិការថ្នាលចុះបញ្ជីអាជីវកម្ម (OBR) តាមរយៈថ្នាល CamDX | **១៩ ១៧៣ ៦០៧**<br>(~១៩ លាន ប្រតិបត្តិការ) |

## ២. ចំនួនពាក្យស្នើសុំអាជ្ញាបណ្ណ/លិខិតអនុញ្ញាត/វិញ្ញាបនបត្រជំនាញ (ដំណាក់កាលទី ២ & ៣)

| គិតពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៤ | |
|---|---|
| **ក្រសួង/ស្ថាប័ន** | **ចំនួនអនុម័តសរុប** |
| ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | ២៣០ |
| ក្រសួងទេសចរណ៍ | ៤១១ |
| ក្រសួងប្រៃសណីយ៍ និង ទូរគមនាគមន៍ | ៤១៧ |
| និយ័តករអចលនវត្ថុ និង បញ្ចាំនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ១៥១ |
| និយ័តករធានារ៉ាប់រងកម្ពុជានៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ | ១៩ ០៤២ |
| បេឡាជាតិសន្តិសុខសង្គម | ៩ ១៣៧ |

## ៣. ស្ថិតិដើមទុនចុះបញ្ជីតាមកម្មវត្ថុអាជីវកម្មទាំង ៥ ដែលមានដើមទុនវិនិយោគចុះបញ្ជីច្រើនជាងគេ

| គិតពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៤ | | | |
|---|---|---|---|
| **ល.រ.** | **បរិយាយ** | **ដើមទុនចុះបញ្ជីសរុប**<br>(១ ដុល្លារអាមេរិក = ៤១០០ រៀល) | **ដើមទុនគិតជា %** |
| ១ | ការសាងសង់អាគារ | **~៤,៨៤** ទ្រីលានរៀល<br>(**~១,១៨** ប៊ីលានដុល្លារអាមេរិក) | **១០,៦១%** |
| ២ | សកម្មភាពអចលនទ្រព្យ ដោយប្រើ អចលនទ្រព្យផ្ទាល់ខ្លួន ឬជួលពីគេ | **~៤,៦២** ទ្រីលានរៀល<br>(**~១,១៣** ប៊ីលានដុល្លារអាមេរិក) | **១០,១២%** |
| ៣ | សកម្មភាពសេវាកម្មស្នាក់នៅ | **~៤,២** ទ្រីលានរៀល<br>(**~១,០២** ប៊ីលានដុល្លារអាមេរិក) | **៩,២%** |
| ៤ | សកម្មភាពពិគ្រោះយោបល់ផ្នែកគ្រប់គ្រង | **~២,៥៣** ទ្រីលានរៀល<br>(**~៦១៨** លានដុល្លារអាមេរិក) | **៥,៥៥%** |
| ៥ | កម្មន្តសាលសម្លៀកបំពាក់ លើកលែងសម្លៀកបំពាក់ធ្វើពីរោមសត្វ | **~២,៤៥** ទ្រីលានរៀល<br>(**~៥៩៨** លានដុល្លារអាមេរិក) | **៥,៣៨%** |
| ៦ | ផ្សេងៗ | **~២៦,៩៨** ទ្រីលានរៀល<br>(**~៦,៥៨** ប៊ីលានដុល្លារអាមេរិក) | **៥៩,១៤%** |

## ៤. ស្ថិតិកម្មវត្ថុអាជីវកម្មទាំង ៥ ដែលមានក្រុមហ៊ុន/សហគ្រាសទទួលបានការចុះបញ្ជីច្រើនជាងគេ

(គិតពីថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០២០ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៤)



សមិទ្ធផលទាំងនេះ គឺជាសមិទ្ធផលរួម ដែលកើតចេញពីកិច្ចខំប្រឹងប្រែង និង ការចូលរួមយ៉ាងសកម្មពីសំណាក់ក្រសួង ស្ថាប័នពាក់ព័ន្ធ ក៏ដូចជាការគាំទ្រយ៉ាងពេញទំហឹង និង ផ្តល់មតិរិះគន់ដើម្បីស្ថាបនាពីធុរជន ជាពិសេសក្រោមមគ្គុទេសក៍ដឹកនាំដ៏ឆ្នើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្នជាប្រធានព្រឹទ្ធសភា ជាមួយនឹងការបន្តយកចិត្តទុកដាក់ និង ជួយជ្រោមជ្រែងដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

CamDX